# ស្ថានីយផូស៊ីលសត្វសមុទ្រ ភ្នំស្វាយ

ភ្នំស្វាយជាស្ថានីយ៍ផូស៊ីលសត្វសមុទ្រ មានទីតាំងស្ថិតនៅក្រុងសិរីសោភណ្ឌ ខេត្តបន្ទាយមានជ័យ មានចំនុចនិយាមកា 279819-1504105។ ភ្នំស្វាយស្ថិតនៅខាងក្រោយសាលាខេត្តបន្ទាយមានជ័យ។ ភ្នំស្វាយ ជាទីតាំងទាក់ទាញភ្ញៀវទេសចរទៅទស្សនា ដ្បិតទីតាំងនេះអាចឱ្យអ្នកទេសចរទស្សនានៅទិដ្ឋភាពដ៏ស្រស់ស្អាត នៃទីរួមខេត្តបន្ទាយមានជ័យពីលើកំពូលនេះបាន។ ម្យ៉ាងទៀតក៏ជាកន្លែងសម្រាប់ប្រជាជនក្នុងខេត្តនិយមដើរហាត់ប្រាណប្រចាំថ្ងៃ ដោយធ្វើដំណើរតាមផ្លូវបេតុងឡើងដល់កំពូលភ្នំតែម្តង(រូបលេខ១)។ ភ្នំស្វាយត្រូវរាជរដ្ឋាភិបាលបានដាក់បញ្ចូលជាតំបន់បេតិកភណ្ឌធម្មជាតិក្នុងឆ្នាំ២០២០។ ដ្បិតអីតំបន់នេះ មានសក្តានុពលផ្នែកធនធានធម្មជាតិ និងធនធានវប្បធម៌។

ភ្នំស្វាយជាប្រភេទភ្នំថ្មកំបោរ ដែលកកជាស្រទាប់ៗ ដែលមានអតីតកាលជាសមុទ្រមានអាយុកាលក្នុងស័កទី១ សម័យ Permian ( ២៥១-២៩៩លានឆ្នាំ)។[៧] ផូស៊ីលត្រូវបានរកឃើញពាសពេញភ្នំ តែវាស្ថិតនៅក្នុងថ្ម។ សំណាកផូស៊ីលដែលបានរកឃើញដូចជាៈ

១. ផូស៊ីលពពួក Crinoid ដែលមានច្រើនជាងគេនៅតាមថ្ម ពីក្រោមរហូតដល់លើ (រូបលេខ២-៣)។ ពពួក Crinoid ស្ថិតនៅក្នុងក្រុមជាមួយពពួកសត្វផ្កាយសមុទ្រ។ ក្នុងនោះ យើងបានប្រទះឃើញផ្នែកខាងក្បាលនៃ Crinoid (រូបលេខ៤)នៅនឹងថ្មមួយដុំដែលនៅចង្កេះភ្នំ ដែលកប់នៅក្នុងថ្មកំបោរ។

២. បំណែកផូស៊ីលត្រីបានរកឃើញកប់លើថ្មតាមផ្លូវឡើងទៅកាន់វត្តក្បែរចង្កេះភ្នំ។ នេះអាចជាផូស៊ីលត្រីទី១នៅប្រទេសយើង(រូបលេខទ៥)។ សំណាកត្រីនេះកប់ក្នុងថ្មមានទំហំតូច ជាក់ស្តែងនៅសល់តែផ្នែកខាងក្បាលបន្តិច និងព្រុយ។ នេះអាចមកពីសំណឹកធម្មជាតិ ឬក៏អាចមកពីការបំបែកថ្មនៅក្បែរផ្លូវឡើងទៅកាន់វត្ត។

៣. ផូស៊ីលផ្កាថ្ម ក៏បានរកឃើញនៅតំបន់នេះផងដែរ ដោយមានបផ្គាញផ្កាថ្មជាច្រើនប្រភេទ ចាំត្រូវធ្វើការសិក្សាលំអិត ដើម្បីកំណត់ពីប្រភេទនៃផ្កាថ្មទាំងនេះ (រូបលេខ៦-៧)។ ដោយឡែកនៅទីតាំងមួយ ស្ថិតនៅតាមផ្លូវឡើងទីកាន់វត្តភ្នំស្វាយបានប្រទះឃើញបំណែកថ្មកំបោរថ្ម៣ដុំ ក្នុងនោះមានបំណែកដុំមួយ មានផ្កាថ្មដែលមានប្រវែង៨០ស.ម។

៤. ពពួក Brachiopods ដែលមានរូបរាងប្រហាក់ប្រហែលងាវនោះ ក៏បានរកឃើញ

---

[៧] General Department of Mineral Resource, 2010, Geological Map of Cambodia

អត្ថបទដោយៈ លឹម វណ្ណច័ន្ទ

តិចតួចដែរ(រូបលេខ៨)។ ប្រភេទមួយទៀតមានសំបកតែម្ខាង មានរូបរាងដូចផ្អឹងត្រី (រូបលេខ៩)

៥. សំណាកផូស៊ីលមួយផ្សេងទៀត មានសណ្ឋានជាផ្នត់ៗហាក់ដូចជាពពួកសារ៉ាយ (រូបលេខ១០)។ មួយវិញទៀតយើងក៏បានជួបប្រទះប្រភេទផូស៊ីលម្យ៉ាងដែលមានរូបរាងប្រហាក់ប្រហែលរុក្ខជាតិមានរាងជាដុំមូលៗតគ្នា និងមានទ្រនុងកណ្តាល តើវាអាចជាផូស៊ីលរុក្ខជាតិទេ? (រូបលេខ១១)។ ចំណុចខ្វះក៏ទាមទារឱ្យមានកិច្ចសហការណ៍ជាមួយអ្នកជំនាញបរទេសផងដែរ ដើម្បីជម្រុញការសិក្សាស្រាវជ្រាវនេះឱ្យកាន់តែលម្អិត។

៦. ផូស៊ីលមួយចំនួនមួយទៀត ដែលបានរកឃើញក៏ពុំទាន់អាចកំណត់អត្តសញ្ញាណបាននៅឡើយ(រូបលេខ១២)។

រួមសេចក្តីមកទីតាំងភ្នំស្វាយនេះ ជាទីតាំងមួយដែលមានតម្លៃសម្រាប់ការសិក្សាស្រាវជ្រាវបែបវិទ្យាសាស្ត្រ ស្តីអំពីជីវៈចម្រុះក្នុងសមុទ្រសម័យបុរាណ ដែលមានអាយុកាលក្នុងសម័យ Permian ( ២៥១-២៩៩លានឆ្នាំ) នាស័កទី១។

AMS អរិយធម៌ខ្មែរ KHMER CIVILIZATION

អត្ថបទដោយ៖ លឹម វណ្ណច័ន្ទ





អត្ថបទដោយៈ លឹម វណ្ណចន្ទ័





អត្ថបទដោយ៖ លឹម វណ្ណច័ន្ទ





អត្ថបទដោយ៖ លឹម វណ្ណចន្ទ







អត្ថបទដោយ៖ លឹម វណ្ណច័ន្ទ





អត្ថបទដោយ៖ លឹម វណ្ណច័ន្ទ





អត្ថបទដោយ៖ លឹម វណ្ណច័ន្ទ